# ជំពូកទី០២

# ក្របខណ្ឌច្បាប់

Draft

គំរោងធ្វើអាជីវកម្មរ៉ែដែក ដែលមានទីតាំងស្ថិតនៅក្នុងស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី របស់ក្រុមហ៊ុន Hoang Ahn Rattanakiri Co., Ltd. ត្រូវបានអនុវត្តន៍ និងគោរពតាមក្របខ័ណ្ឌច្បាប់ជាច្រើនរបស់ព្រះរាជាណាចក្រកម្ពុជា។ ជំពូកនេះ គឺគ្រាន់តែរៀបរាប់ និងបកស្រាយពីភាពពាក់ព័ន្ធនៃច្បាប់ និងអនុក្រឹត្យមួយចំនួន ដែលមានទំនាក់ទំនងផ្ទាល់នឹងដំណើរការនៃការអនុវត្តន៍គំរោង និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមនៃគំរោងវិនិយោគនេះប៉ុណ្ណោះ។

## ២.១. ច្បាប់ពាក់ព័ន្ធ

### ២.១.១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996)

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/1296/36 ចុះថ្ងៃទី24 ខែធ្នូ ឆ្នាំ1996 មានគោលដៅ: (i) ការពារ លើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល (ii) វាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គម មុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង (iii) ធានាឱ្យមានការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា (iv) លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណ:ជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង (iv) បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់បរិស្ថាន (មាត្រា01)។ ច្បាប់នេះបានលើកឡើងពីតំរូវការជាច្រើនដែលនីតិបុគ្គល និងម្ចាស់គំរោងវិនិយោគ ត្រូវអនុវត្ត និងគោរពតាម (ឧ. តំរូវការនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងអភិវឌ្ឍន៍)។

ច្បាប់នេះក៏បានលើកឡើងពីតួនាទី-ភារ:កិច្ចរបស់ក្រសួងបរិស្ថានក្នុងការទប់ស្កាត់ កាត់បន្ថយ និងត្រួតពិនិត្យរាល់ការបំពុលបរិស្ថានផ្សេងៗ (ឧ. បរិយាកាស ទឹក ដី ការរំខានដោយសំលេង-រំញ័រ សំណល់) និងផ្តល់សិទ្ធិដល់ក្រសួងបរិស្ថានក្នុងការចាត់វិធានការផ្លូវច្បាប់ (ឧ. បញ្ជាឱ្យកែប្រែសកម្មភាពល្មើស ផាកពិន័យ ផ្អាក និងបញ្ឈប់សកម្មភាព) ចំពោះបុគ្គលណា ដែលប្រព្រឹត្តល្មើសនឹងការកំណត់របស់ក្រសួងបរិស្ថាន និងធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន។

### ២.១.២. ច្បាប់ស្តីពីព្រៃឈើ (2002)

ច្បាប់ស្តីពីព្រៃឈើ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/0802/016 ចុះថ្ងៃទី31 ខែសីហា ឆ្នាំ2002។ ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានគោលបំណងធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវ:ចំរុះ និងមរតក



Draft

វប្បធម៌ ។ ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី ។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផលអនុផលព្រៃឈើ របស់សហគមន៍មូលដ្ឋាននៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

មាត្រា52 បានលើកឡើងថា "រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រមូលផល អនុផលព្រៃឈើសំរាប់គោលដៅពាណិជ្ជកម្មលើព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិ តាមរយៈរដ្ឋបាលព្រៃ-ឈើ ។ រាជរដ្ឋាភិបាលត្រូវកំណត់ថ្លៃសួយសារ និងបុព្វលាភ ផ្អែកតាមសំណើរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។

យោងតាមខ្លឹមសារនៃច្បាប់នេះ ប្រសិនបើម្ចាស់គំរោងមានបំណងធ្វើពាណិជ្ជកម្មទៅលើព្រៃឈើ ឬបង្កឱ្យមានការបាត់បង់ព្រៃឈើដែលមាននៅក្នុងទីតាំងគំរោងរបស់ខ្លួន ម្ចាស់គំរោងត្រូវរៀបចំគិតគូរអំពីការប្រមូលផល អនុផលព្រៃឈើ និងការបង់ថ្លៃ សួយសារ និងបុព្វលាភចូលថវិកាជាតិ ។

### ២.១.៣. ច្បាប់ស្តីពីជលផល (2006)

ច្បាប់ស្តីពីជលផល ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/0506/011 ចុះថ្ងៃទី21 ខែឧសភា ឆ្នាំ2006 ។ ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចំរុះផង មរតកវប្បធម៌ធម្មជាតិផង និងប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិ ទាំងជលផលកែច្នៃ និងទាំងវារីវប្បកម្ម ។ រដ្ឋធានាសិទ្ធិប្រើប្រាស់ធនធានជលផលជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

មាត្រា18 បានបង្ហាញឱ្យឃើញថា "តំបន់គ្រប់គ្រងជលផលជាអាទិ៍តំបន់ទឹកជំនន់ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹង ទន្លេសាប បឹង ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផលត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារ និងអភិរក្សធនធានជលផល" ។ ជាមួយគ្នានេះដែរ មាត្រា20 ក៏បានបញ្ជាក់បន្ថែមអំពី "ការហាមឃាត់ដាច់ខាត ចំពោះការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទ ដោយប្រើឧបករណ៍ផ្សេងៗដែលបង្កមហន្តរាយដល់ធនធានជលផលដូចជា ឧបករណ៍ឆក់ គ្រឿងផ្ទុះ សារធាតុពុលគ្រប់ប្រភេទ ឧបករណ៍បូម បាច ពង្រីងជាដើម" ។ មាត្រា22 ក៏បានបង្ហាញឱ្យឃើញអំពី "ការហាមឃាត់ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុល ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុ-សញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ" ។

Draft

យោងតាមខ្លឹមសារនៃច្បាប់នេះ ទោះបីជាទីតាំងគំរោងពុំបានស្ថិតនៅក្នុងតំបន់គ្រប់គ្រងរបស់ជលផលក៏ដោយ ក៏នៅក្នុងទីតាំងគំរោងមានអូរមួយចំនួន ដែលជាមរតកវប្បធម៌ធម្មជាតិ ដូច្នេះក្រុមហ៊ុនត្រូវប្រុងប្រយ័ត្នជានិច្ចក្នុងការធានាឱ្យបានថា សកម្មភាពគំរោងរបស់ខ្លួន (ដូចជា ការចាក់ចោល ការបង្ហូរនូវកាកសំណល់រឹង-រាវ ឬសារធាតុពុល) ពុំបានបង្កឱ្យមានមហន្តរាយដល់ធនធានទាំងនេះ។ បន្ថែមពីលើនេះទៀត ក្រុមហ៊ុនក៏ត្រូវអប់រំ និងដាក់ពិន័យតឹងរឹងដល់បុគ្គលិក-កម្មកររបស់ខ្លួន ដោយមិនឱ្យបង្កសកម្មភាពណា (ដូចជា ការប្រើឧបករណ៍ឆក់ គ្រឿងផ្ទុះ) ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានជលផល ជាពិសេសធនធានត្រី។

### ២.១.៤. ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (2008)

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/1209/026 ចុះថ្ងៃទី13 ខែឧសភា ឆ្នាំ2008។ ច្បាប់នេះមានគោលដៅកំណត់គោលការណ៍ជាបទដ្ឋាន សំរាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល និងសំរាប់រៀបចំច្បាប់ហិរញ្ញវត្ថុ ជាពិសេសសំរាប់ជំហ៊ានទីមួយៗនៃដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិកា ការត្រួតពិនិត្យលទ្ធផលថវិកា ការកំណត់មុខងារ ការទទួលខុសត្រូវព្រមទាំងកម្មវិបាកលើកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលនឹងគ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ច្បាប់នេះមានគោលបំណងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយគោរពគោលការណ៍បូរណភាព អាជ្ញាភាព ឯកត្តភាព សមាគតភាព សកលភាព សង្គតិភាព គណនេយ្យភាព ស្ថិរភាព ភាពគ្រប់ជ្រុងជ្រោយ និងសមិទ្ធិកម្ម។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គ្របដណ្តប់ទាំងហិរញ្ញវត្ថុសាធារណៈជាតិ ទំនាក់ទំនង និងអន្តរសកម្មរវាងហិរញ្ញវត្ថុអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុ ឯកជន អន្តរជាតិ ហើយត្រូវធានាការគោរពគោលការណ៍ថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ភាពភ្ជាប់គ្នារវាងថវិកា និងគោលនយោបាយ និងគណនេយ្យភាពចំពោះសមិទ្ធិកម្ម។ បន្ថែមពីនេះទៀត ច្បាប់នេះមានវិសាលភាពជាច្បាប់គោល ដែលត្រូវយកធ្វើជាមូលដ្ឋាន និងត្រូវគោរពអនុវត្តតាម សំរាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា17បានចែងថា "ទ្រព្យសម្បត្តិដែលរួមមាន ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវចាត់ចែង និងគ្រប់គ្រងយ៉ាងត្រឹមត្រូវទៅតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលើការលក់ ការជួល ការផ្ទេរ និងការចាត់ចែង ដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ព្រមទាំងការធ្វើបញ្ជីសារពើភ័ណ្ឌ។ រាល់ការចុះកិច្ច សន្យាលើទ្រព្យសម្បត្តិរដ្ឋ និងផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ដែលមានការពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការឯកភាពរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

បន្ថែមពីលើនេះទៀត អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ (2005) បានចែងនៅត្រង់មាត្រា02ថា "រាជរដ្ឋាភិបាល គឺជាអ្នកគ្រប់គ្រងរាល់

Draft

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ និងរបស់នីតិបុគ្គលសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការលក់ ការដូរ និងការជួលនូវទ្រព្យសម្បត្តិរបស់រដ្ឋ ។

អនុលោមទៅតាមខ្លឹមសារដូចរៀបរាប់ខាងលើនេះ តំបន់ស្រុកបរកែវ និងស្រុកអូរយ៉ាដា ខេត្តរតនគិរី គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយទីតាំងនេះអាចចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីស្នើសុំបាន ក្រោមលក្ខខណ្ឌជួល ឬសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យធ្វើអាជីវកម្មរ៉ែបាន តាមរយៈការស្នើសុំទៅស្ថាប័នជំនាញមានសមត្ថកិច្ច។ ផ្ទៃដីដែលត្រូវបានស្នើសុំដូចកំណត់ខាងលើ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួង-ស្ថាប័នជំនាញមានសមត្ថកិច្ចជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

### ២.១.៥. ច្បាប់ភូមិបាល (2001)

ច្បាប់ភូមិបាល ដែលបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/0801/14 ចុះថ្ងៃទី30 ខែសីហា ឆ្នាំ2001 មានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ ស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ1993នៃព្រះរាជាណាចក្រកម្ពុជា។

ផ្អែកតាមមាត្រា15នៃច្បាប់នេះ តំបន់ធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន អាចចាត់ចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ ហើយដោយផ្អែកតាមមាត្រា16នៃច្បាប់នេះ តំបន់នេះមិនអាចលក់ដូរ ឬដាក់នៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសនៃជំពូកទី4នៃច្បាប់នេះបានទេ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងនេះនៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ។ ផ្ទុយទៅវិញ យោងទៅលើមាត្រា17នៃច្បាប់នេះ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធិតាមការកំណត់ដោយច្បាប់។ ទ្រព្យទាំងនោះអាចផ្តល់ឱ្យតាមរយៈភតិសន្យា និងជាកម្មវត្ថុនៃកិច្ចសន្យាដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់។ លក្ខខណ្ឌទាំងឡាយ និងនីតិវិធីនៃការលក់ និងការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ នឹងកំណត់ដោយអនុក្រឹត្យ។ គ្មានការលក់ណាមួយ អាចត្រូវបានសំរេចដោយគ្មានអនុក្រឹត្យនេះឡើយ។ ដីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃសម្បទានក្នុងលក្ខខណ្ឌដែលមានចែងក្នុងជំពូកទី05នៃច្បាប់នេះ។

ដោយអនុលោមទៅតាមខ្លឹមសារដូចរៀបរាប់ខាងលើនេះ ទីតាំងតំរោងដែលស្ថិតនៅក្នុងស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន តាមរយៈការស្នើសុំទៅរាជ-

Draft

រដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ច ជាពិសេសក្នុងករណីដែលទីតាំងនេះបានបាត់បង់ផលប្រយោជន៍សាធារណៈ ឬផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់សេដ្ឋកិច្ចជាតិ។ ដោយផ្អែកលើមាត្រាទាំងឡាយនៅក្នុង**ជំពូកទី05**នៃច្បាប់នេះ ទីតាំងនេះអាចត្រូវបានផ្តល់ជាសម្បទានទៅឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់ និងប្រើ-ប្រាស់សិទ្ធិលើដីឱ្យឆ្លើយតបទៅនឹងផលប្រយោជន៍សង្គម ឬទៅនឹងផលប្រយោជន៍សេដ្ឋកិច្ច ប៉ុន្តែសម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សំរាប់ថែទាំ ក៏ដូចជាផ្លូវទឹក ត្រពាំង បឹង និង ដែនទឹកបំរុង ដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ។ នីតិវិធីនៃការផ្តល់សម្បទានដីសំរាប់ការសាងសង់លំនៅ-ដ្ឋាន និងសម្បទានដីកសិកម្មសំរាប់ការចិញ្ចឹមជីវិត ឬអាជីវកម្មរ៉ែត្រូវកំណត់ដោយអនុក្រឹត្យ ហើយរយៈពេលនៃសម្បទានដីត្រូវកំណត់99ឆ្នាំយ៉ាងច្រើន។

### ២.១.៦. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក (2007)

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកលេខ នស/រកម/0607/016 ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី 22 ខែឧសភា ឆ្នាំ2007 ក្នុងគោលបំណងលើកតំឡើងការគ្រប់គ្រងធនធានទឹកឱ្យមានប្រសិទ្ធភាព និងចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យបានសំរេចនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងសុខមាលភាពរបស់ប្រជា-ពលរដ្ឋដោយធ្វើការកំណត់: (i) សិទ្ធ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់ទឹក (ii) គោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងធនធានទឹក និង (iii) ការចូលរួម និងភាពពាក់ព័ន្ធរបស់អ្នកប្រើប្រាស់នៅក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃធនធានទឹក (មាត្រា01)។ ផ្អែកតាមច្បាប់នេះ ក្រសួងធនធានទឹក និងឧតុនិយម គឺជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងធនធានទឹក និងកំណត់នូវបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានទឹក។

ក្នុងន័យនេះ ប្រសិនបើគំរោងអភិវឌ្ឍន៍ធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. នេះ អាចនឹងត្រូវការប្រើប្រាស់ទឹកជាច្រើនដើម្បីបំពេញតំរូវការនៃការធ្វើអាជីវកម្ម ក្រុមហ៊ុនត្រូវពិភាក្សា និង/ឬ សុំការអនុញ្ញាតពីក្រសួងធនធានទឹក និងឧតុនិយម នូវរាល់សកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងការទាញយកទឹកមកប្រើប្រាស់នៅក្នុងខ្សែសង្វាក់អាជីវកម្មរបស់ខ្លួន។ ជាក់ស្តែង ក្រុមហ៊ុននឹងរៀបចំអាងស្តុកទឹក និងប្រើប្រាស់ទឹកជាប្រព័ន្ធវិលចុះវិលឡើង (Recycle) ដោយរក្សានូវការប្រើប្រាស់ទឹកសន្សំសំចៃតាមដែលអាចធ្វើទៅបាន ដើម្បីចៀសវាងការដណ្តើមទឹកប្រើប្រាស់ពីប្រជាពលរដ្ឋ ជាពិសេសនៅរដូវប្រាំង។

Draft

### ២.១.៧. ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (2006)

ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រ (2006) មានវិសាលភាពចំពោះគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលធ្វើឡើងដោយបុគ្គលណាមួយ។ មានតែគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់នេះ (មាត្រា01) ដែលផលប្រយោជន៍ទាំងនោះរួមមាន ការលើកទឹកចិត្តដូចជាការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយ និងពន្ធអាករ (មាត្រា13)។ គំរោងវិនិយោគមានលក្ខណៈសម្បត្តិ

គ្រប់គ្រាន់ គឺជាគំរោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ( មាត្រា02) ហើយរាល់បុគ្គល ដែលមានបំណងបង្កើតគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមទំរង់ និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះ និងអនុក្រឹត្យ ( មាត្រា06) ។

## ២.១.៤. ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (2001)

ច្បាប់ដែលពាក់ព័ន្ធដំបូងបំផុតសំរាប់គំរោងអភិវឌ្ឍន៍លើគំរោងធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន គឺច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/0701/09 ចុះថ្ងៃទី13 ខែកក្កដា ឆ្នាំ2001 ។ ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើអណ្តូងរ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយ ដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែនៅព្រះរាជាណាចក្រកម្ពុជា ។ លើកលែងតែប្រតិបត្តិការប្រេងកាត និងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក ( មាត្រា01) ។ ធនធានរ៉ែទាំងអស់ដែលឋិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាសម្បត្តិរដ្ឋ ។

ប្រតិបត្តិការធនធានរ៉ែ គឺជាការធ្វើសកម្មភាពបុរេសនាស្វែងរក និងអាជីវកម្មធនធានរ៉ែ ។ បុរេសនា គឺជាការស្វែងរុករកជំហ៊ានដំបូងនៅស្រទាប់ដីលើដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែតំលៃពាណិជ្ជកម្ម និងអាចជាទិសដៅសំរាប់ការស្នើសុំអាជ្ញាប័ណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។ ការស្វែងរុករក គឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ចអាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត ។

អាជីវកម្មធនធានរ៉ែ គឺជាប្រតិបត្តិការជីកយកធនធានរ៉ែ ដែលក្នុងនោះធនធានរ៉ែត្រូវបានយកចេញពីជំរករ៉ែធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម ។ ដោយឡែកការលក់ដូរ ការនាំចេញការនាំចេញលោហៈធាតុមានតំលៃ ត្បូងថ្មមានតំលៃដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមាន ។ អាជីវកម្មធនធានរ៉ែ គឺជាប្រតិបត្តិការជីកយកធនធានរ៉ែដែលក្នុងនោះធនធានរ៉ែ ត្រូវបានយកចេញពីជំរករ៉ែធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ការនាំចេញ ការនាំចូលលោហៈធាតុមានតំលៃ ត្បូងថ្មមានតំលៃ ដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ( មាត្រា03) ។

អាជ្ញាប័ណ្ណធនធានរ៉ែ គឺជាលិខិតអនុញ្ញាតិដែលផ្តល់នូវសិទ្ធិទៅសម្បទានិក ដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តសកម្មភាពប្រតិបត្តិការធនធានរ៉ែ ( មាត្រា04) ។

Draft

អាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានរៀបចំជា06ប្រភេទ ដើម្បីសំរួលដល់អ្នកដាក់ពាក្យសុំក្នុងគោលដៅសំរួលការគ្រប់គ្រងលើការងារស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធិភាព។

- អាជ្ញាប័ណ្ណស្វែងរុករក: អាចផ្តល់ឱ្យចំពោះរូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីស្វែងរុករក និងសិក្សាអំពីសក្តានុពលធនធានរ៉ែ។
- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ: ត្រូវបានផ្តល់ឱ្យចំពោះតែសម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករកប៉ុណ្ណោះក្នុងគោលបំណងស្វែងរុករក និងជីកយករ៉ែណា ដែលមានជំរករ៉ែមានប្រសិទ្ធិភាពសេដ្ឋកិច្ច ហើយឋិតនៅតែក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក។ សម្បទានិកស្វែងរុករក ត្រូវតែដាក់ឱ្យពិនិត្យនូវការវិភាគបច្ចេកទេស ហិរញ្ញវត្ថុ បរិស្ថាន សេដ្ឋកិច្ច និងសង្គមក្នុងគោលបំណងកំណត់លទ្ធភាពសេដ្ឋកិច្ច-សង្គមនៃទំរង់ប្រតិបត្តិការជីកយករ៉ែ ដើម្បីសុំការយល់ព្រមពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។ បែបបទ និងមាតិកានៃរបាយការណ៍ការសិក្សាអំពីសមិទ្ធិលទ្ធភាពចុងក្រោយ និងឯកសារយោង ព្រមទាំងលក្ខខ័ណ្ឌទាំងឡាយនៃការចេញអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ នឹងមានចែងក្នុងអនុក្រឹត្យ។

ជំពូកទី05 មាត្រាទី21នៃច្បាប់នេះបញ្ជាក់យ៉ាងច្បាស់ថា "សម្បទានិក ឬអ្នកចុះកិច្ចសន្យាបន្តនីមួយៗ ត្រូវទទួលខុសត្រូវលើការដឹកនាំប្រតិបត្តិការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ នឹងត្រូវអនុវត្តទៅតាមការកំណត់ដូចខាងក្រោម:

- ដំណើរការប្រតិបត្តិការឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពតាមលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុ ដែលនឹងលំអិតក្នុងកម្មវិធីការងារស្វែងរុករក ឬការសិក្សាអំពីសមិទ្ធិលទ្ធភាពអណ្តូងរ៉ែ។
- ការពារបរិស្ថាន ដូចមានលំអិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែ និងការធានាផ្នែកហិរញ្ញវត្ថុ។
- ធានាការពារសុខភាព និងសុវត្ថិភាពពលករដែលនឹងលំអិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាព និងសុវត្ថិភាពក្នុងអណ្តូងរ៉ែ រាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពីគ្រោះថ្នាក់នេះ។
- ការពារសុវត្ថិភាពដល់សាធារណៈជននៅក្នុង និងជុំវិញតំបន់អណ្តូងរ៉ែ ដែលនឹងលំអិតក្នុងផែនការអណ្តូងរ៉ែ។
- ធ្វើការអប់រំ បណ្តុះបណ្តាល និងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរ ដែលនឹងលំអិតក្នុងកម្មវិធីផ្តល់ការងារ អប់រំបណ្តុះបណ្តាល។
- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវទំនិញ និងសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជា នៅតាមកន្លែង និងពេលវេលាសមស្រប។

ជាមួយគ្នានេះដែរ មាត្រា25បានចែងថា សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវសងទៅម្ចាស់កម្មសិទ្ធិដីទាំងក្នុង និងក្រៅតំបន់អាជ្ញាប័ណ្ណធនធានរ៉ែ ចំពោះការខូចខាតទាំងឡាយ ដែលបណ្តាលមកពីប្រតិបត្តិការអាជីវ-

Draft

កម្មធនធានរ៉ែរបស់ខ្លួនដោយមិនគិតថា ការខូចខាតនោះជាឧបទ្ទវហេតុ ឬជាការដឹងមុន។ ក្នុងករណីការខូចខាតណាដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់សម្បទានិកចាប់ពី02រូប ឡើងទៅ សម្បទានិកទាំងនោះត្រូវរួមគ្នាសងទៅតាមការខូចខាត។ សំណងទាំងនោះត្រូវអនុវត្តន៏ដូចខាងក្រោមនេះ:

- ប្រសិនបើជាតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ ប៉ះពាល់ទៅលើដីកម្មសិទ្ធិ ម្ចាស់ដីត្រូវអនុញ្ញាតិឱ្យសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ធ្វើប្រតិបត្តិការធនធានរ៉ែនៅលើដីនោះ ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមកជាមុន ដែលក្នុងនោះម្ចាស់ដីត្រូវបានទទួលសំណងសមរម្យ និងយុត្តិធម៌
- សំណងនោះត្រូវសងតាមពេលវេលា ឬសងផ្តាច់តែម្តងតាមការព្រមព្រៀងរវាងម្ចាស់ដី និងសម្បទានិក ដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ
- ក្នុងករណីម្ចាស់ដី និងសម្បទានិក ដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ មិនអាចស្រុះស្រួលគ្នាលើសំណងបានទេនោះ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវសំរបសំរួលដោះស្រាយ បើមិនបានសំរេចទេត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាល ដើម្បីបង្កើតគណៈកម្មាធិការចំរុះមួយសំរបសំរួលដោះស្រាយករណីនេះ
- ក្នុងករណីដែលភាគីទាំងអស់ មិនយល់ព្រមតាមដំណោះស្រាយរបស់គណៈកម្មាធិការចំរុះទេនោះ សេចក្តីសំរេចជាសមត្ថកិច្ចរបស់តុលាការ។

ម៉្យាងវិញទៀត ក្នុងករណីដែលផ្ទៃដីទាំងមូល ឬចំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ មិនទាន់បានផ្តល់កម្មសិទ្ធិជូនទៅបុគ្គលណាម្នាក់ទេនោះ អាជ្ញាធរមានសមត្ថកិច្ចមិនអាចចេញកម្មសិទ្ធិផ្ទៃដីទាំងមូល ឬចំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែទៅឱ្យបុគ្គលណាម្នាក់បានឡើយ លើកលែងតែមានការអនុញ្ញាតិពីរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ (មាត្រា26)។ ប្រសិនបើតំបន់ប្រតិបត្តិការអាជ្ញាប័ណ្ណធនធានរ៉ែនោះមានប្រជាពលរដ្ឋកំពុងរស់នៅ មុនកាលបរិច្ឆេទនៃការចេញអាជ្ញាប័ណ្ណ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែត្រូវអនុវត្តសំណងដូចមានចែងក្នុងមាត្រា25ដែរ។

ផ្អែកតាមខ្លឹមសារនៃច្បាប់នេះ ប្រសិនបើម្ចាស់ក្រុមហ៊ុនមានបំណងធ្វើអាជីវកម្មរ៉ែ (ដែក) ដែលមាននៅក្នុងទីតាំងស្នើសុំ ម្ចាស់ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ តាមរយៈស្ថាប័នទទួលបន្ទុកវិស័យរ៉ែ (ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល)។ ដូច្នេះជាផ្នែកមួយដើម្បីឱ្យទទួលបានអាជ្ញាប័ណ្ណនេះ ម្ចាស់ក្រុមហ៊ុនត្រូវគោរព អនុវត្តន៏ និងទទួលខុសត្រូវលើការការពារបរិស្ថាន ដូចមានចែងលំអិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (1996) នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងន័យនេះ ម្ចាស់ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍ស្តីពីការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ក៏ដូចជាផែនការគ្រប់គ្រងបរិស្ថាន ដូចមានរៀបរាប់នៅក្នុងរបាយការណ៍នេះ។

Draft

## ២.២. អនុក្រឹត្យពាក់ព័ន្ធ

### ២.២.១. អនុក្រឹត្យស្តីពីអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (1999)

អនុក្រឹត្យនេះត្រូវបានរៀបចំឡើងដើម្បីអនុវត្ត និងបំពេញបន្ថែមនូវបញ្ញត្តិនានា ដែលមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ(1996) ជាពិសេសពាក់ព័ន្ធនឹងការងារវាយតំលៃហេតុប៉ះ-ពាល់បរិស្ថាននៃគំរោងអភិវឌ្ឍន៍នានា។ អនុក្រឹត្យនេះត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី11 ខែសីហា ឆ្នាំ1999 ក្នុងគោលបំណង: (i) កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណ: ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសំរេច (ii) កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន និងសាធារណ: ដែលត្រូវវាយតំហៃហេតុប៉ះពាល់បរិស្ថាន និង (iii) បំផុសឱ្យមានការចូលរួមពីសាធារណ:ជនក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគំរោង (មាត្រា01)។ ប្រភេទ និងទំហំគំរោង/សកម្មភាព ដែលត្រូវបំពេញតាមតំរូវការនៃអនុក្រឹត្យនេះ (ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គម) មានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

### ២.២.២. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (1999)

អនុក្រឹត្យនេះត្រូវបានរៀបចំឡើងដើម្បីអនុវត្ត និងបំពេញបន្ថែមនូវបញ្ញត្តិនានា ដែលមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996) ជាពិសេសពាក់ព័ន្ធនឹងការងារត្រួតពិនិត្យសកម្ម-ភាព និងប្រភពដែលនាំឱ្យមានការបំពុល ឬធ្វើឱ្យខូចគុណភាពទឹក។ អនុក្រឹត្យនេះត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី06 ខែមេសា ឆ្នាំ1999 ក្នុងគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់-បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណ: សំដៅធានាឱ្យបានការការពារមនុស្ស និងអភិរក្សជីវ:ចំរុះ (មាត្រា01) ហើយអនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណ: (មាត្រា02)។ អនុក្រឹត្យនេះក៏បានដាក់ចេញនូវកំរិតស្តង់ដារ និងបញ្ញត្តិនានាលើការបញ្ចេញសំណល់រាវពីប្រភពបំពុលផ្សេងៗ។

### ២.២.៣. អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (1999)

អនុក្រឹត្យនេះត្រូវបានរៀបចំឡើងដើម្បីអនុវត្ត និងបំពេញបន្ថែមនូវបញ្ញត្តិនានាដែលមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996) ជាពិសេសពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំណល់រឹង-សំរាម។ អនុក្រឹត្យនេះត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី27 ខែមេសា ឆ្នាំ1999 ក្នុងគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹងប្រកបដោយលក្ខណ:បច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាឱ្យបាន

Draft

នូវកិច្ចការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ (មាត្រា01) ហើយអនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ (មាត្រា02) ។

### ២.២.៤. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង-រំញ័រ (2000)

អនុក្រឹត្យនេះត្រូវបានរៀបចំឡើងដើម្បីអនុវត្ត និងបំពេញបន្ថែមនូវបញ្ញត្តិនានាដែលមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996) ជាពិសេសពាក់ព័ន្ធនឹងការងារត្រួតពិនិត្យសកម្ម-ភាព និងប្រភពដែលនាំឱ្យមានការបំពុលខ្យល់ និងការរំខានដោយសំលេង-រំញ័រ ។ អនុក្រឹត្យនេះត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី10 ខែកក្កដា ឆ្នាំ2000 ក្នុងគោលបំណងដើម្បីការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈពីសារធាតុបំពុលខ្យល់ក្នុងបរិយាកាស និងការរំខានដោយសំលេង តាមរយៈសកម្មភាពត្រួតពិនិត្យទប់ស្កាត់ និងកាត់បន្ថយ (មាត្រា01) ហើយអនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងអស់ ដែលបង្កឱ្យមានការបំពុលខ្យល់ និងសំលេងនៅក្នុងបរិយាកាស (មាត្រា02) ។

### ២.២.៥. អនុក្រឹត្យស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (2006)

អនុក្រឹត្យស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (2006) មានគោលដៅដើម្បីបំពេញបន្ថែម និងចាត់ចែងគ្រប់គ្រងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (2006) និងមានគោលដៅជំរុញការលើកទឹកចិត្ត និងធ្វើនិយ័តកម្មលើការវិនិយោគទាំងឡាយរបស់នីតិបុគ្គលសញ្ជាតិខ្មែរ និងនីតិបុគ្គលសញ្ជាតិបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះអនុវត្តទៅលើរាល់គំរោងវិនិយោគមានលក្ខណៈគ្រប់គ្រាន់ទាំងអស់ ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សា និងនៅអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (មាត្រា01) ។

ផ្អែកតាមខ្លឹមសារដូចរៀបរាប់ខាងលើ ក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. អាចទទួលបាននូវការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជាដូចជា ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយ-ពន្ធអាករ ក្នុងករណីដែលក្រុមហ៊ុននេះ ដាក់សំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា និងទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

Draft